# ការសំរបសំរួលគោលនយោបាយជាតិ សំរាប់អនុវត្ត និងអភិវឌ្ឍបន្តនូវអនុសញ្ញា
## BC, CITES, CBD & MP

ដោយ ជួន ច័ន្ទបុទ្ធី

សិក្ខាសាលាបណ្តុះបណ្តាលថ្នាក់ជាតិ

"លើកកំពស់កិច្ចសំរបសំរួលគោលនយោបាយជាតិលើវិស័យពាណិជ្ជកម្ម និងបញ្ហាបរិស្ថាន"

ថ្ងៃទី ៥-៦ ខែតុលា ឆ្នាំ២០០៤ សណ្ឋាគារមីកាសា រាជធានីភ្នំពេញ កម្ពុជា

# មាតិកា


- ប្រវត្តិ និងសេចក្តីផ្តើម
- ការសំរបសំរួលគោលនយោបាយជាតិសំរាប់ការអនុវត្តន៏កិច្ចព្រមព្រៀងពហុភាគីស្តីពីវិស័យបរិស្ថាន
  - ការអនុវត្តន៍អនុសញ្ញាបាសែល
  - ការអនុវត្តន៍អនុសញ្ញាស្តីពីពាណិជ្ជកម្មអន្តរជាតិលើប្រភេទជីវរូបកម្រ
  - ការអនុវត្តន៍អនុសញ្ញាស្តីពីជីវចំរុះ
  - ការអនុវត្តន៍ពិធីសាម៉ុងរ៉េអាល់
- សេចក្តីសន្និដ្ឋាន


# ១. ប្រវត្តិ និងសេចក្តីផ្តើម

- ការប្តេជ្ញាចិត្តនៃរាជរដ្ឋាភិបាលក្នុងការអនុវត្តន៏កម្មវិធីកំណែទំរង់លើគ្រប់វិស័យ ដើម្បីកាត់បន្ថយភាពក្រីក្រ និងសំរេចឱ្យបាននូវការអភិវឌ្ឍន៏វិស័យសេដ្ឋកិច្ច និងសង្គមកិច្ចប្រកបដោយចីរភាព
  - កម្មវិធីនយោបាយ រៀបរៀងដោយបក្សនយោបាយជាដៃគូ
  - គោលនយោបាយចតុកោណ
  - គោលដៅអភិវឌ្ឍសហស្សវត្ស
  - កម្មវិធីអភិវឌ្ឍវិស័យសេដ្ឋកិច្ច-សង្គមកិច្ចកម្ពុជា ២០០១-២០០៥
  - យុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ ២០០៣-២០០៥ ព្រមទាំង
  - គោលនយោបាយ យុទ្ធសាស្ត្រ ផែនការ និងកម្មវិធីកំណែទំរង់សំខាន់ៗដ៏ទៃទៀត

- ដើម្បីធានាបាននូវការការពារបរិស្ថាន និងការអភិវឌ្ឍន៏ដោយចីរភាព
  - ធម្មនុញ្ញបានបង្កើតក្រសួងបរិស្ថាន (១៩៩៣) ឱ្យដោះស្រាយបញ្ហាបរិស្ថានដែលកើតចេញពីការអភិវឌ្ឍន៏វិស័យនានា។
  - រាជរដ្ឋាភិបាលបានផ្តល់អាទិភាពខ្ពស់ឱ្យក្រសួងរៀបចំ/តាក់តែងច្បាប់ គោលនយោបាយ យុទ្ធសាស្ត្រ ផែនការបរិស្ថាន សំរាប់ដោះស្រាយបញ្ហាទាំងឡាយនោះ និងមានក្តីកង្វល់លើការគ្រប់គ្រងបរិស្ថានដោយនិរន្តរភាព និងការប្រើប្រាស់ធនធានធម្មជាតិប្រកបដោយចីរភាព។

- ការខិតខំប្រឹងប្រែងលើឆាកអន្តរជាតិ
  - ក្រៅពីការខិតខំក្នុងប្រទេស (ការតាក់តែង និងការអនុវត្តន៍គោលនយោបាយបរិស្ថាន) កម្ពុជា ជាភាគីហត្ថលេខីលើអនុសញ្ញា កតិកាសញ្ញា ពិធីសា និងកិច្ចព្រមព្រៀងថ្នាក់តំបន់ និងអន្តរជាតិមួយចំនួន ពាក់ព័ន្ធទៅនឹងការអភិវឌ្ឍន៍ដោយចីរភាព កិច្ចការពារបរិស្ថាន ការអភិវឌ្ឍន៍ធនធានមនុស្ស និងការលើកកំពស់សហប្រតិបត្តិការថ្នាក់តំបន់ ។ល។
  - បច្ចុប្បន្ន កិច្ចព្រមព្រៀងទាំងនេះ ផ្តល់នូវមាគ៌ាច្បាស់លាស់សំរាប់ដំណើរការក្នុងក្របខ័ណ្ឌនៃការរៀបចំ/តាក់តែង និងការអនុវត្តន៍គោលនយោបាយ យុទ្ធសាស្ត្រ និងផែនការបរិស្ថាន ។ល។

# ២. ការសំរបសំរួលគោលនយោបាយជាតិ
## សំរាប់
## ការអនុវត្តន៏កិច្ចព្រមព្រៀងពហុភាគីស្តីពីវិស័យបរិស្ថាន

## ២.១ ការអនុវត្តន៍អនុសញ្ញាបាសែល

- **ប្រវត្តិ និងសេចក្តីផ្តើម**
  - សន្និសញ្ញាបរិស្ថានពិភពលោក សំដៅ
    - *ដាក់កំហិត និងត្រួតពិនិត្យនូវចលនាពីតំបន់មួយទៅមួយនៃសំណល់គ្រោះថ្នាក់ (ជាតិពុល) និងការទុកដាក់របស់វា នៅថ្នាក់ជាតិ និងអន្តរជាតិ*
    - *ជំរុញការកសាងសមត្ថភាពក្នុងការគ្រប់គ្រងសំណល់គ្រោះថ្នាក់ ជាពិសេសនៅតាមបណ្តាប្រទេសកំពុងអភិវឌ្ឍន៍*
  - កម្ពុជា បានចុះហត្ថលេខានៅថ្ងៃទី ២ ខែមិនា ឆ្នាំ២០០១ តែពុំទាន់បានផ្តល់សច្ចាប័ននៅឡើយទេ។

- **ការកសាងសមត្ថភាព**
  - គំរោងជំនួយបច្ចេកទេសស្តីពី "ការគ្រប់គ្រងសំណល់អាគុយនៅកម្ពុជា" ដែលឧបត្ថម្ភដោយអង្គការ UNEP/SBC និងចាប់អនុវត្តពីខែធ្នូ ឆ្នាំ២០០៣ ដល់ខែកញ្ញា ឆ្នាំ២០០៤
  - បំណងប្រាំយ៉ាងនៃគំរោង
    - *កំណត់លំហូរអាគុយដោយការប្រើប្រាស់ ការគ្រប់គ្រងសំណល់អាគុយ ការប៉ះពាល់ដល់បរិស្ថាន និងសុខភាពរបស់មនុស្ស*
    - *កំណត់កង្វះចន្លោះក្នុងការគ្រប់គ្រងសំណល់អាគុយ*
    - *រៀបចំផែនការសកម្មភាពសំរាប់ការគ្រប់គ្រងសំណល់អាគុយ*
    - *លើកកំពស់ការយល់ដឹងជាសាធារណ:ស្តីពីការគ្រប់គ្រងសំណល់អាគុយ ចលនានៃសំណល់អាគុយពីកន្លែងមួយទៅមួយ និង*
    - *លើកកំពស់ការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធ។*

- ការអនុវត្តន៍គំរោង ផ្អែកលើកម្មវិធីធំ២ពីរដែលបានរៀបចំ គឺ:
  - *ការសិក្សានៅនឹងកន្លែង*
  - *ការចុះស្រាវជ្រាវដល់កន្លែង (ទីតាំងតាមខេត្ត/ក្រុង ។ល។)*

- **ការពង្រឹងស្ថាប័ន/ការរៀបចំការិយាល័យ**
  - អនុក្រឹត្យស្តីពីការគ្រប់គ្រងសំណល់រឹង និងសារធាតុមានជាតិពុលពីឧស្សាហកម្ម អនុម័តនាឆ្នាំ១៩៩៩
  - ការិយាល័យសំរបសំរួលគំរោង ឋិតនៅក្នុងក្រសួងបរិស្ថាន កំពុងព្រៀងផែនការសកម្មភាពជាតិស្តីពី "ការគ្រប់គ្រងសំណល់អាគុយ ដោយពុំប៉ះពាល់ដល់បរិស្ថាន" ផ្អែកលើការសិក្សាស្រាវជ្រាវ

- គោលបំណងនៃផែនការសកម្មភាព រួមមាន:
  - *រៀបចំគោលការណ៍ណែនាំពាក់ព័ន្ធទៅនឹងការគ្រប់គ្រងអាគុយ និងសំណល់អាគុយ*
  - *លើកកំពស់ការយល់ដឹងជាសាធារណ: និងផលប៉ះពាល់ដល់បរិស្ថាន និងសុខភាព*
  - *កសាងសមត្ថភាពជាតិ និងលើកកំពស់សហប្រតិបត្តិការរវាងវិស័យសាធារណ: និងឯកជន រួមទាំងអង្គការក្រៅរដ្ឋាភិបាល និងគ្រឹះស្ថានសិក្សា*
  - *បង្កើតបណ្តាញទាក់ទង ក្នុងនិងក្រៅប្រទេស សំរាប់ការផ្លាស់ប្តូរព័ត៌មាន ការផ្តល់បច្ចេកវិទ្យាសំរាប់ការគ្រប់គ្រង និងការកែឆ្នៃប្រើឡើងវិញនៃសំណល់អាគុយប្រកបដោយប្រសិទ្ធភាព។*

## ២.២ ការអនុវត្តន៍អនុសញ្ញា CITES

- **ប្រវត្តិ និងសេចក្តីផ្តើម**
  - អនុសញ្ញាវ៉ាស៊ីនតោន ហៅថា "សាយតេស" សំដៅ:
    - *ការពារប្រភេទរុក្ខជាតិ សត្វ ដោយការដាក់កំហិត ត្រួតពិនិត្យ និងតាមដានលើការជួញដូររុក្ខជាតិ សត្វទាំងឡាយនោះជាអន្តរជាតិ កុំឱ្យផុតពូជលើលោក។*
  - ចូលជាធរមាននៅឆ្នាំ១៩៧៥
  - កម្ពុជា បានចុះហត្ថលេខានៅឆ្នាំ១៩៧៣ បន្ទាប់មកក្លាយជាភាគីនៅឆ្នាំ១៩៩៧
  - មានជាង១៧០ប្រទេសជាសមាជិក
  - លេខាធិការដ្ឋាន គ្រប់គ្រងដោយអង្គការ UNEP

- កម្ពុជាប្រឈមទៅនឹងការជួញដូរប្រភេទសត្វ-រុក្ខជាតិដោយខុសច្បាប់
- ការប្តេជ្ញាចិត្តរបស់រដ្ឋាភិបាល  និងការគាំទ្រអនុសញ្ញាទាំងស្រុង
- ឧបករណ៍តែមួយគត់ក្នុងការស្រោចស្រង់ប្រភេទសត្វ-រុក្ខជាតិ
- ដោយសារអ្នកមានទ្រព្យចង់បានប្រើប្រាស់

- **ការកសាងសមត្ថភាព  និងការរៀបចំស្ថាប័ន**
  - ក្រសួងកសិកម្ម  រុក្ខាប្រមាញ់  និងនេសាទ
    - *អាជ្ញាធរជាតិសំរាប់ការគ្រប់គ្រង*
    - *អាជ្ញាធរស្រាវជ្រាវវិទ្យាសាស្ត្រ  -  នាយកដ្ឋានជលផល  និង  រដ្ឋបាលព្រៃឈើ*

- **អាជ្ញាធរជាតិសំរាប់ការគ្រប់គ្រង**
  - ចេញលិខិតអនុញ្ញាត  លិខិតបញ្ជាក់ផ្លូវការ  តាមគោលការណ៍ណែនាំនៃអនុសញ្ញា  និងសហប្រតិបត្តិការជាមួយលេខាធិការដ្ឋាន  និងភាគីដ៏ទៃ

- **អាជ្ញាធរស្រាវជ្រាវវិទ្យាសាស្ត្រ**
  - នាយកដ្ឋានជលផល  ទទួលបន្ទុកគ្រប់គ្រងវារីជលផល  និង
  - រដ្ឋបាលព្រៃឈើ  ទទួលបន្ទុកគ្រប់គ្រងរុក្ខជាតិ-សត្វលើគោក

- តួនាទីនៃស្ថាប័នពីរនេះ  រួមមាន:
  - *ផ្តល់យោបល់ដល់អាជ្ញាធរជាតិសំរាប់ការគ្រប់គ្រងលើការស្នើសុំនាំចេញនូវប្រភេទសត្វ-រុក្ខជាតិណាមួយដែលមានចែងក្នុង  ឧបសម្ព័ន្ធទី១  និងទី២*
  - *ត្រួតពិនិត្យ  តាមដានលើលិខិតអនុញ្ញាតនាំចេញនូវប្រភេទសត្វ-រុក្ខជាតិដូចមានចែងក្នុងឧបសម្ព័ន្ធទី២  និងផ្តល់នូវយន្តការសមស្របជូនអាជ្ញាធរជាតិមុននឹងចេញលិខិតអនុញ្ញាត  និង*
  - *រកជំរើសសមស្រប  ដើម្បីរាយការណ៍ជូនអាជ្ញាធរជាតិ  សំរាប់ការសង្គ្រោះសត្វព្រៃដែលបានចាប់/ដកហូតពីអ្នករំលោភ។*

- ក្រសួងបរិស្ថាន  មានតួនាទីសំខាន់ណាស់  ដូចជា:
  - *ក្នុងការគ្រប់គ្រងតំបន់ការពារទាំង២៣  របស់ជាតិ  សំរាប់កិច្ចការពារ  និងការអភិរក្សសត្វព្រៃ-រុក្ខជាតិ*
  - *រៀបចំយន្តការសំរាប់ការអនុវត្តន៍អនុសញ្ញាសាយតេស  ជាពិសេស  ជួយសំរួលសហប្រតិបត្តិការអន្តរជាតិលើបញ្ញត្តិស្តីពីការជួញដូរសត្វព្រៃ  និងរុក្ខជាតិ។*
- ការចុះហត្ថលេខាលើអនុស្សារណៈ(២០០២)  រវាងអាជ្ញាធរជាតិគ្រប់គ្រងអនុសញ្ញា  CITES  និង  អង្គការ  TRAFFIC
  - *ធ្វើការរួមគ្នា  ដើម្បីពង្រឹងការអនុវត្តន៍អនុសញ្ញាសាយតេស*

— សហប្រតិបត្តិការជាមួយអង្គការផ្សេងៗទៀតដូចជា U.S. DoI, CI, WildAid, WWF, etc.

- *បណ្តុះបណ្តាលមន្ត្រីរាជការស្តីពីការអនុវត្តន៍អនុសញ្ញា រួមទាំងនីតិវិធីក្នុងការចេញលិខិត បទដ្ឋានអនុញ្ញាតលើការដួញដូរសត្វ-រុក្ខជាតិ*
- *ពង្រាងបទបញ្ញត្តិស្តីពីការអនុវត្តន៍អនុសញ្ញាសាយតេស (ខែកក្កដា ឆ្នាំ២០០៤)*
- *ផ្តល់ឧបករណ៍ សម្ភារៈប្រើប្រាស់សំរាប់ធ្វើការ ដល់អាជ្ញាធរជាតិគ្រប់គ្រងសាយតេស*

- ក្រាហ្វិកនេះ បង្ហាញនូវទិន្នន័យប្រភេទសត្វ និងរុក្ខជាតិ ដែលកំពុងទទួលរងនូវការគំរាមកំហែង ពីឆ្នាំបរបាញ់ល្មើសច្បាប់។
- ទិន្នន័យនេះ ត្រូវបានគណនាដោយ ***វិទ្យាស្ថានធនធានពិភពលោក*** ផ្អែកលើសំរង់ និងការវិភាគទិន្នន័យពីក្នុងតំបន់ការពារធម្មជាតិ ដោយប្រើប្រព័ន្ធវាស់ទីតាំងវត្ថុលើផែនដី។




# ២.៣ ការអនុវត្តន៍អនុសញ្ញាជីវចំរុះ CBD

- **ប្រវត្តិ និងសេចក្តីផ្តើម**
  - ការចុះហត្ថលេខាលើអនុសញ្ញា ផ្តើមឡើងនៅឯសន្និសីទអង្គការសហប្រជាជាតិស្តីពី "បរិស្ថាន និងការអភិវឌ្ឍន៍" ឆ្នាំ១៩៩២
  - ចូលជាធរមាននៅថ្ងៃទី ២៩ ខែធ្នូ ឆ្នាំ១៩៩៣
  - មានសមាជិកជាង១៧០ប្រទេសចូលរួម
  - ប្រទេសកម្ពុជា បានចុះហត្ថលេខាក្នុងឆ្នាំ១៩៩២ និងផ្តល់សច្ចាប័ន នៅថ្ងៃទី ៩ ខែកុម្ភៈ ឆ្នាំ១៩៩៥

— កម្ពុជា ឋិតក្នុងមហាអនុតំបន់មេគង្គ មានបឹងទន្លេសាប ទន្លេបឹងបួរផ្សេងទៀត ព្រៃប្រឹក្សា សមុទ្រ សំបូរណ៍ដោយជីវចំរុះច្រើនបែបយ៉ាង ទាំងក្នុងទឹកសាប សមុទ្រ និងនៅលើដី

— អាកាសធាតុត្រូពិក សីតុណ្ហភាព ទឹកភ្លៀង សំណើម ។ល។

— សំរាប់ជាព៏តមានស្តីពីប្រភេទជីវចំរុះសំខាន់ៗនៅកម្ពុជា

- *តំបន់ទន្លេសាប:*
  - ក្រឡាផ្ទៃ មានប្រមាណ ២៥០,០០០ ហិកតា នារដូវប្រាំង
  - ប្រភេទរុក្ខជាតិ មានចំនួនប្រមាណ ២០០ប្រភេទ
  - ប្រភេទមច្ឆាជាតិ មានចំនួនប្រមាណ ២១៥ប្រភេទ/៥០០ប្រភេទក្នុងទូទាំងប្រទេស
  - ប្រភេទថនិកសត្វ មានចំនួនប្រមាណ ៤៦ប្រភេទ
  - ប្រភេទសត្វស្លាប មានចំនួនប្រមាណ ២២៥ប្រភេទ និង ១៥ប្រភេទថនិកសត្វ រស់ក្នុងតំបន់បឹង និងតាមវាលទំនាបមកក្រោម ។ល។

- **ការរៀបចំស្ថាប័ន និងការកសាងសមត្ថភាពជាតិ**
  - ធម្មនុញ្ញកម្ពុជា ត្រង់មាត្រាទី៥៨ និងទី៥៩:
    - *បរិយាយល្អិតល្អន់ពីច្បាប់នានាពាក់ព័ន្ធដល់ការគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន*
    - *រដ្ឋត្រូវយកចិត្តទុកដាក់ការពារបរិស្ថាន រក្សាឱ្យបាននូវតុល្យភាពធនធានធម្មជាតិ ដ៏សំបូរណ៍បែប និងរៀបចំបង្កើតផែនការគ្រប់គ្រងដី ទឹក ខ្យល់ ។ល។ និង។ល។*
  - ក្រសួងបរិស្ថាន ត្រូវបានបង្កើតឡើងដើម្បីដោះស្រាយទៅនឹងបញ្ហាបរិស្ថាន ជំរុញកិច្ចការពារ និងអភិរក្សធនធានធម្មជាតិនិងបរិស្ថាន និងអនុវត្តច្បាប់ ក្រឹត្យ អនុក្រឹត្យ។ល។ ដើម្បីរួមចំណែកក្នុងការលើកកំពស់គុណភាពបរិស្ថាន សុខុមាលភាពសាធារណៈ ប្រពៃណីជាតិ និងការអភិវឌ្ឍន៍សេដ្ឋកិច្ចដោយចីរភាព ។ល។

- រាជរដ្ឋាភិបាលបានប្តេជ្ញាអនុវត្តអនុសញ្ញានេះប្រកបដោយប្រសិទ្ធភាពខ្ពស់ តាមរយៈកម្មវិធីអភិរក្សរបស់ខ្លួន រួមសហការជាមួយក្រសួងពាក់ព័ន្ធ ជាអាទិ៍ MAFF, MLMUPC, MoP, MoWRAM, MRD, etc. និងអង្គការអន្តរជាតិមួយចំនួនទៀត រួមមាន: IUCN, WWF, WCS, WI, CI, FFI, UNEP, UNDP, DANIDA, MRC, etc.
  - *គំរោងនានាដែលបាន និងកំពុងអនុវត្ត រួមមាន:*

*(សូមបន្តទៅ ឧបសម្ព័ន្ធទី១)*

- សមិទ្ធិផលធំៗ សំរេចបានមកទល់ពេលនេះ រួមមាន:
  - *រាជក្រឹត្យស្តីពីតំបន់ការពារធម្មជាតិទូទាំងប្រទេស ឆ្នាំ១៩៩៣ - ១៨%/ផ្ទៃដីសរុប*
  - *ព្រៃបំរុង/ការពារ ឆ្នាំ២០០៣ ប្រមាណ ៧%/ផ្ទៃដីសរុប*
  - *រាជក្រឹត្យស្តីពីការគ្រប់គ្រងតំបន់ជីវមណ្ឌលបឹងទន្លេសាប ឆ្នាំ២០០១*
  - *យុទ្ធសាស្ត្រ និងផែនការសកម្មភាពជាតិស្តីពីជីវចំរុះ*
  - *ក្របខ័ណ្ឌជីវសុវត្ថិភាពជាតិ ។ល។*

## ២.៤ ការអនុវត្តន៍ពិធីសារម៉ុងរ៉េអាល់ MP

- **ប្រវត្តិ និងសេចក្តីផ្តើម**
  - កិច្ចព្រមព្រៀងអន្តរជាតិ សំដៅការពារស្រទាប់អូហ្សូនក្នុងស្រាតូស្ពែរ
  - ចុះហត្ថលេខាដំបូងនៅឆ្នាំ១៩៨៧
  - ចូលជាធរមាននៅឆ្នាំ១៩៨៩
  - កម្ពុជាបានចុះហត្ថលេខានៅឆ្នាំ១៩៨៨ និង ????????????? នៅថ្ងៃទី ២៧ ខែមិថុនា ឆ្នាំ២០០១ ?????

- **ការកសាងសមត្ថភាព និងការរៀបចំស្ថាប័ន**
  - មានចែងក្នុងរបាយការណ៍ស្តីពីគោលដៅអភិវឌ្ឍសហស្សវត្ស ឆ្នាំ២០០៣ ត្រង់គោលដៅទី៧ ដើម្បីធានានិរន្តរភាពបរិស្ថាន។
  - ក្រសួងបរិស្ថាន រួមជាមួយស្ថាប័នពាក់ព័ន្ធ មាននាទីរៀបចំយុទ្ធសាស្ត្រ និងផែនការជាតិ ដើម្បីធានានូវសុខភាពសាធារណៈ និងការការពារបរិស្ថាន អំពីឥទ្ធិពលបណ្តាលដោយការបំផ្លាញស្រទាប់អូហ្សូន។

- គំរោងមួយចំនួន កំពុងត្រូវបានអនុវត្តជំហានដំបូង (ឧបសម្ព័ន្ធទី២)
- នាយកដ្ឋានត្រួតពិនិត្យការបំពុលបរិស្ថាន ដែលក្នុងនោះការិយាល័យអូហ្សូនជាតិត្រូវបានបង្កើតឡើង គឺជាភាគីប្រតិបត្តិគំរោងខាងលើ ។ល។

## ៣. សេចក្តីសន្និដ្ឋាន

- រាជរដ្ឋាភិបាលយកចិត្តទុកដាក់ និងប្តេជ្ញាចិត្តខ្ពស់ក្នុងការអនុវត្តន៍កិច្ចព្រមព្រៀងអន្តរជាតិទាំងបួន
- កង្វះធនធានមនុស្ស និងបច្ចេកទេស ការិតការអនុវត្តន៍
- ត្រូវការជំនួយបច្ចេកទេសពីសហគមន៍ផ្តល់ជំនួយសំរាប់ការបណ្តុះបណ្តាល
- កង្វះយុទ្ធសាស្ត្រ និងផែនការសកម្មភាពជាតិតាមបែបសមាហរណកម្ម លើវិស័យពាក់ព័ន្ធ
- ការសំរបសំរួល សហប្រតិបត្តិការរវាងស្ថាប័ននិងស្ថាប័ន មានការិតនៅឡើយ
- កង្វះទិន្នន័យ/ព័តមានសំរាប់ការរៀបចំយុទ្ធសាស្ត្រ និងផែនការសកម្មជាតិ
- ការសំរេចលើអ្វីមួយ ពុំបានសិក្សា ពិនិត្យគ្រប់ជ្រុងជ្រោយ
- ការចូលរួមពីសាធារណជនក្នុងការអនុវត្តន៍ច្បាប់ មានការិតនៅឡើយ ដូចនេះ ការលើកកំពស់ការយល់ដឹងជាសាធារណៈសំរាប់ការចូលរួម គឺជាអាទិភាពមួយខ្ពស់ក្នុងការជំរុញការអនុវត្តន៍អនុសញ្ញាខាងលើ ។ល។

## សូមអរគុណ

Thanks So Much for Your Attention

Contact:
chanrithy_ch@hotmail.com